**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៦.០៩៧/០៨ គ.ជ.ប.អគ្គ.ពស**

ភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨

# លទ្ធផលបណ្តោះអាសន្ននៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

គិតចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតចំនួន **៥,៧៨៩,៨០៧** នៃប័ណ្ណព័ត៌មានសរុបចំនួន **៨,១២៥,៥២៩** ត្រូវបានផ្តល់ជូនដល់អ្នកបោះឆ្នោតទូទាំងប្រទេស។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា រហូតមកដល់ពេលនេះក្រុមចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត បានចែកដល់អ្នកបោះឆ្នោតស្មើនឹង ៧១.២៥%។ ឯកឧត្តមបានបញ្ជាក់ថា ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតសរុបទូទាំងប្រទេសមានចំនួន ៨,១២៥,៥២៩ ប័ណ្ណ ស្មើនឹងចំនួនអ្នកបោះឆ្នោតដែលមានក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០០៧ ចំនួន ៨,១២៥,៥២៩ នាក់ ហើយកំពុងធ្វើការចែកចាយដល់អ្នកបោះឆ្នោតចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨។ ឯកឧត្តមបានបន្ថែមថា ក្រោយពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨ ប័ណ្ណព័ត៌មានដែលនៅសល់ពីការចែកចាយត្រូវរក្សាទុកនៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) ហើយបើអ្នកបោះឆ្នោតពុំទាន់បានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនេះអាចមកទទួលយកប័ណ្ណព័ត៌មាននេះនៅ គឃ/សប រហូតដល់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៨ វេលាម៉ោង ៥:៣០ នាទីល្ងាច។

សូមបញ្ជាក់ថា ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ជាប័ណ្ណសម្រាប់ជូនព័ត៌មានដល់អ្នកបោះឆ្នោតឱ្យដឹងអំពី÷

- កាលបរិច្ឆេទ និងពេលវេលានៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៧ ខែកក្កដា ឆ្នាំ២០០៨ ដោយចាប់ផ្តើមពីម៉ោង ៧:០០ ព្រឹក រហូតដល់ម៉ោង ៣:០០ រសៀល
- ទីតាំង និងលេខកូដការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលអ្នកត្រូវទៅបោះឆ្នោត
- លេខរៀង ឈ្មោះ ទិន្នន័យពាក់ព័ន្ធនឹងសាមីខ្លួនក្នុងបញ្ជីបោះឆ្នោត ព្រមទាំងប្រភេទឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការសម្រាប់ប្រើប្រាស់នៅពេលបោះឆ្នោត។ បើគ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោតក៏អ្នកបោះឆ្នោតអាចទៅបោះឆ្នោតបានដែរ ឱ្យតែមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងយកទៅជាមួយនូវឯកសារបញ្ជាក់អត្តសញ្ញាណណាមួយនៅថ្ងៃបោះឆ្នោត។